**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣៧១២១ កសក

# សេចក្តីណែនាំ
# ស្តីពី
# វិធានការរក្សាទឹកទុក ការថែទាំ និងប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៥ ព្រមទាំងការត្រៀមលក្ខណៈបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦

នៅចុងរដូវវស្សាឆ្នាំ២០១៥នេះ អាកាសធាតុមានការប្រែប្រួល និងមានភ្លៀងធ្លាក់តិចតួចនៅដើមរដូវដោយតំបន់ ហើយចាប់ពីពាក់កណ្តាលខែកក្កដារហូតដល់ចុងខែសីហា គ្រោះរាំងស្ងួតបានកើតមាននៅតាមបណ្តាខេត្តមួយចំនួនដែលធ្វើឱ្យការងារដាំដុះដំណាំស្រូវ មានការយឺតយ៉ាវជាងឆ្នាំមុន និងធ្វើឱ្យខូចខាតសំណាបចំនួន ៦៤ហ.ត និងស្រូវសន្ទូងនិងពង្រោះចំនួន១៤.០៤៤ហ.ត។ ទោះជាយ៉ាងណាក៏ដោយ គិតមកត្រឹមថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥ អនុវត្តបានចំនួន ២.៥៥១.៥១៤ហ.ត ស្មើនឹង៩៩.៣៩% នៃផែនការ ២.៥៦៧.១៣០ហ.ត តិចជាងឆ្នាំមុនចំនួន៦.០៥៩ហ.ត។ ក្នុងគោលបំណងដើម្បីបង្កើនទិន្នផលស្រូវឱ្យបានច្រើនជាអតិបរមា និងកាត់បន្ថយនូវការបាត់បង់ស្រូវអង្ករ ទាំងបរិមាណ និងគុណភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ និងមន្ទីរកសិកម្មរាជធានី-ខេត្តទូទាំងប្រទេស ត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធ្វើការណែនាំដល់ប្រជាកសិករ ផលិតករ និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យអនុវត្តនូវវិធានការចាំបាច់មួយចំនួនដូចខាងក្រោម៖

## I. ការរក្សាទឹកទុក ការថែទាំ និងប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៥

១. ត្រូវជំរុញការថែទាំស្រូវក្នុងស្រែឱ្យបានល្អតាមរយៈ៖

- ការមើលថែទាំអាងស្តុកទឹក ទំនប់ប្រឡាយនិងប្រព័ន្ធភ្លឺស្រែឱ្យបានគត់មត់ល្អ ដើម្បីរក្សាទឹកទុកក្នុងអាងនិងក្នុងស្រែឱ្យបានគ្រប់គ្រាន់ និងសន្សំសំចៃខ្ពស់ចៀសវាងការខ្វះទឹកនៅចុងរដូវនៅពេលស្រូវមិនទាន់ទុំល្អ ។
- ការថែបំប៉នដំណាំស្រូវដោយប្រើប្រាស់ជីឱ្យបានត្រឹមត្រូវតាមបច្ចេកទេសស្របតាមដំណាក់កាលលូតលាស់របស់ដំណាំស្រូវ ដើម្បីផ្តល់សារធាតុចិញ្ចឹមឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការ សំដៅជំរុញការលូតលាស់ឱ្យល្អនិងផ្តល់ទិន្នផលខ្ពស់។
- ការអនុវត្តវិធានការចម្រុះការពារដំណាំឱ្យបានម៉ឺងម៉ាត់ដើម្បីទប់ស្កាត់និងកម្ចាត់សមាសភាពចង្រៃ រួមមានស្មៅ សត្វចង្រៃ និងជំងឺដែលអាចកើតមានជាយថាហេតុ ធានាការបាត់បង់បរិមាណផលនិងរក្សាបាននូវគុណភាពស្រូវអង្ករ។

២. ត្រូវបង្ហូរទឹកចេញពីស្រែនៅពេលដែលគ្រាប់ស្រូវភាគច្រើនដាក់ម្សៅរឹងនិងប្រែពណ៌ទៅជាលឿង ឬប្រមាណជា១សប្តាហ៍មុនពេលច្រូតកាត់ ដើម្បីកាត់បន្ថយការខូចគុណភាពគ្រាប់នៅពេលស្រូវដួលដើម ហើយមានភាពងាយស្រួលក្នុងការច្រូតកាត់និងដឹកជញ្ជូន។

៣. ត្រូវច្រូតស្រូវនៅពេលទុំល្អ ពោលគឺនៅពេលដែលគ្រាប់ស្រូវទុំបានប្រមាណ៨០% ទៅ៨៥%។ ចៀសវាងការច្រូតកាត់នៅពេលគ្រាប់ស្រូវស្ងួតជ្រុល ដែលអាចបណ្តាលឱ្យជ្រុះច្រើន និងងាយប្រេះស្រាំនៅពេលបោកបែនហើយបាក់គ្រាប់អង្ករច្រើន។ ប៉ុន្តែ មិនត្រូវច្រូតស្រូវនៅពេលគ្រាប់ស្រូវជាច្រើនមិនទាន់ទុំ(ទុំស្ទើរ) ពីព្រោះធ្វើឱ្យពិបាកបោកបែន បាត់បង់ផល អង្ករបាក់ច្រើន និងមានសម្បុរមិនស្អាតល្អ។

៤. ត្រូវធ្វើការច្រូតកាត់និងបោកបែនស្រូវដោយប្រុងប្រយ័ត្ន ចៀសវាងការធ្វើឱ្យគ្រាប់ស្រូវបែកនិងប្រេះស្រាំ ដែលងាយទទួលរងការបំផ្លាញពីជំងឺនិងសត្វចង្រៃនានានៅពេលទុកដាក់ ព្រមទាំងធ្វើឱ្យគ្រាប់អង្ករបាក់ច្រើន។

៥. ត្រូវហាលសម្ងួតគ្រាប់ស្រូវឱ្យបានឆាប់តាមតែអាចធ្វើទៅបានបន្ទាប់ពីច្រូតកាត់ ព្រោះការរក្សាទុកឬផ្តាប់គ្រាប់ស្រូវសើមលើសពី២៤ម៉ោង គុណភាពស្រូវអង្ករចាប់ផ្តើមថយចុះ។ អត្រាសំណើមគ្រាប់ស្រូវសមស្របសម្រាប់ទុកបរិភោគ គឺ១៤% និង១២-១៣% សម្រាប់ទុកធ្វើគ្រាប់ពូជ។

៦. ត្រូវសម្អាតគ្រាប់ស្រូវឱ្យបានស្អាតល្អនិងរក្សាទុកឱ្យបានត្រឹមត្រូវ មានខ្យល់ចេញចូលគ្រប់គ្រាន់ និងមានអនាម័យល្អ ចៀសវាងការធ្វើឱ្យគ្រាប់ស្រូវសើមនិងឡើងកម្តៅ ដើម្បីទប់ស្កាត់ការបំផ្លាញរបស់សត្វចង្រៃនិងជំងឺផ្សេងៗ ទើបអាចរក្សាបរិមាណនិងគុណភាពគ្រាប់ស្រូវឱ្យបានល្អ។

## II. ការត្រៀមលក្ខណៈបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦

១. ត្រូវសិក្សាវាយតម្លៃនិងរៀបចំផែនការផលិតកម្មឱ្យបានច្បាស់លាស់ ដោយពិនិត្យទៅលើស្ថានភាពប្រភពទឹកនិងបរិមាណទឹកដែលមាននៅតាមតំបន់នីមួយៗ ព្រមទាំងរក្សាទឹកទុកសម្រាប់ការបង្កបង្កើនផលស្រូវរដូវប្រាំង ដើម្បីចៀសវាងការខ្វះទឹកស្រោចស្រពនៅចុងរដូវបណ្តាលឱ្យថយចុះទិន្នផលឬបាត់បង់ទិន្នផលស្រូវទាំងស្រុង។

២. ត្រូវប្រើប្រាស់ពូជស្រូវស្រាលមិនប្រកាន់រដូវដែលមានរយៈពេលលូតលាស់ខ្លី និងប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អ ពោលគឺ មានភាពសុទ្ធនិងអត្រាដំណុះខ្ពស់ គ្មានគ្រាប់ស្មៅចង្រៃ ភ្នាក់ងារបង្កជំងឺ និងគ្មានសត្វចង្រៃសម្រាប់ធ្វើការដាំដុះ។

៣. ត្រូវរៀបចំយន្តការសិក្សាវាយតម្លៃនិងតាមដានវត្តមានសត្វកណ្តុរឱ្យបានម៉ត់ចត់និងជាប្រចាំ ពីព្រោះប្រជាករសត្វនេះ អាចកើនឡើងខ្ពស់ដោយសារជោរទឹកតូច មិនលិចជម្រករបស់វាដែលជាកត្តាអំណោយផលដល់ការបង្កកំណើតលឿននាំឱ្យមានហានីភ័យខ្ពស់ក្នុងការបំផ្លាញដំណាំស្រូវប្រាំង។ លើសពីនេះទៀត ត្រូវលើកទឹកចិត្តកសិករឱ្យរៀបចំយុទ្ធនាការកម្ចាត់កណ្តុរជាលក្ខណៈសហគមន៍(Community Rat Control Compaign) ជាពិសេសនៅពេលចាប់ផ្តើមធ្វើការដាំដុះស្រូវ។

៤. ត្រូវរៀបចំផែនការចុះផ្សព្វផ្សាយបច្ចេកទេសដាំដុះនិងការពារដំណាំដែលផ្តល់ទិន្នផលខ្ពស់ មានប្រសិទ្ធភាពសេដ្ឋកិច្ចនិងមាននិរន្តរភាពប្រព័ន្ធបរិស្ថានដល់កសិករ។ លើសពីនេះទៀត ត្រូវត្រៀមផ្សោបាយចុះជួយអន្តរាគមន៍ ឱ្យបានទាន់ពេលវេលា នៅពេលមានបញ្ហាកើតឡើងនៅទីវាល។

ទទួលបាននូវសេចក្តីណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន ព្រមទាំងកសិករ/

ម្ចាស់ម៉ាស៊ីនកិនស្រូវ និងអ្នកទិញ-លក់ស្រូវអង្ករ មានវិធានការជាបន្ទាន់ដោយប្រើប្រាស់កម្លាំងសរុបដើម្បីជំរុញការថែទាំស្រូវវស្សានិងការត្រៀមលក្ខណៈដាំដុះស្រូវប្រាំងឱ្យទទួលបានលទ្ធផលល្អ ព្រមទាំងទប់ស្កាត់ការបាត់បង់ទាំងបរិមាណនិងគុណ-ភាពស្រូវអង្ករនៅពេលប្រមូលផល សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឱ្យទទួលបានជោគជ័យ ក្នុងន័យធានាបាននូវសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ បង្កើនសន្ទុះការនាំចេញអង្ករ និងការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ខែតុលា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត អ៊ុក រ៉ាប៊ុន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ក្រសួងផែនការ
- ក្រសួងពាណិជ្ជកម្ម
- អាជ្ញាធរជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងព័ត៌មាន
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី - ខេត្ត

    "ដើម្បីជូនជ្រាប"
- អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្មរាជធានី - ខេត្ត

    "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ